# ការសរសើរ និងការទិតៀនសិស្ស

( Students´ Praise and Criticism )

ដោយៈ **បណ្ឌិត សូ សុធីរ**

មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

រាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

នៅប្រទេសកម្ពុជា តាំងពីអតីតកាលមកដល់សតវត្សទី២០ ការគ្រប់គ្រងសកម្មភាពសិស្ស ត្រូវបានគ្រូ ជាអ្នកចាត់ចែងរៀបចំទាំងអស់ គឺប្រើភាពផ្តាច់ការទាំងស្រុង។ មាតាបិតាសិស្ស ដែលយកកូនទៅចូលរៀន បានផ្តែផ្តាំគ្រូ តាំងពីថ្ងៃដំបូងថា ធ្វើអ្វី ចំពោះកូនរបស់គាត់ បានគ្រប់យ៉ាង ប៉ុន្តែសូមទុកតែភ្នែក និងឆ្អឹង មានន័យថា កុំឱ្យគ្រូ ធ្វើទណ្ឌកម្មសិស្ស ប៉ះពាល់ដល់ភ្នែក និងបាក់ឆ្អឹង។

គ្រូអក្សរសាស្ត្រនៅមធ្យមសិក្សាទុតិយភូមិម្នាក់ បាននិយាយថា ស្នាមដំបៅផ្ទៃនៅជើងគាត់នេះ ជាស្នាមដែលបន្សល់ដោយគ្រូរបស់គាត់ បានវាយគាត់រហូតបែកឈាម និងដំបៅ ហើយនៅពេលដំបៅជាសះស្បើយ វាមានបន្សល់ស្នាកស្នាមនេះ។ មូលហេតុដោយគ្រាន់តែគាត់សូត្រចាំព្យញ្ជនៈ ២ឬ៣វគ្គដែលគ្រូកំពុងសរសេរនៅលើក្តារ ខៀន តែពេលគ្រូ សួរហើយចង្អុលព្យញ្ជនៈនីមួយៗ គាត់មិនអាចប្រាប់បានទេ។ លោកគ្រូគាត់ខឹងជាខ្លាំង ហើយវាយគាត់ ដោយមិនបានសរសើរលើកទឹកចិត្តទេ[1]។

ចូរសាកល្បងពិសោធគំនិតមួយ។ គ្រូឧទ្ទេសម្នាក់ ដែលមានបទពិសោធ នឹងសង្កេតរាល់មេរៀនរបស់គ្រូក្នុងចំណោម មេរៀន៣០។ ឧបមាថា គ្រូ ទើបតែបានបង្រៀនមេរៀនដំបូង។ គេបានសង្កេត ហើយគ្រូកំពុងរៀបចំសម្ភារៈចេញ នៅពេលដែលសិស្សចុងក្រោយ បានចាកចេញពីថ្នាក់ រៀន។ វាគ្រាន់តែជាមេរៀនទី៣ឬទី៤ ដែលគ្រូធ្លាប់បានបង្រៀន។ ដូច្នោះ ជាធម្មតា គ្រូមានអារម្មណ៍ធូរស្រាល នៅពេលដែលគ្រូបង្រៀនចប់ ហើយអន្ទះសាចង់ស្តាប់ពីរបៀប ដែលខ្លួនបានបង្រៀន។ ដោយស្មានទុកជាមុន គ្រូ មិនមានហេតុផល

---

[1] បទសម្ភាសអតីតលោកគ្រូអក្សរសាស្ត្រកម្រិតឧត្តម ស្តីពីរង្វាន់ និងទណ្ឌកម្មទៅលើសិស្ស នៅសាលាគរុកោសល្យ និងវិក្រឹតការកំពត ឆ្នាំ១៩៩៤។

ណា នឹងមិនទុកចិត្តការវិនិច្ឆ័យរបស់គ្រូឧទ្ទេសទេ។ តើអ្វីដែលជាផលនៃចម្លើយលើទំនុកចិត្តនៃចលករសិក្សា អត្រាការងារគ្រូ?

១-គ្រូឧទ្ទេស ដើរចេញទៅក្រៅថ្នាក់រៀន ដោយមិននិយាយអ្វីទាំងអស់។

២-គ្រូឧទ្ទេស សរសើរគ្រូហួសហេតុ សរសើរផ្នែកផ្សេងៗនៃមេរៀន ដែលគ្រូ រៀបចំមិនបានល្អក៏ដោយ។

៣-គ្រូឧទ្ទេសផ្តល់ឱ្យគ្រូនូវការវិភាគពិស្តារពីកំហុសនីមួយៗ ដែលគ្រូបានប្រព្រឹត្តដោយប្រាប់គ្រូ ពីរបៀបកែកំហុស និងបញ្ជាក់ថា គ្រូ គួរតែព្យាយាមកែលម្អសមត្ថភាពរបស់ខ្លួន។

៤-គ្រូឧទ្ទេសសរសើរគ្រូនូវចំណុចមេរៀនមួយចំនួន ប៉ុន្តែ រិះគន់បញ្ហាមួយចំនួនទៀត ហើយបញ្ចប់ដោយនិយាយថា និយាយរួម គ្រូបានប្រឹងប្រែងល្អណាស់ ហើយមេរៀនគាត់កំពុងត្រូវបានកែលម្អ។

៥-គ្រូ ទទួលបាននូវបន្សំគ្នារវាងការសរសើរ និងការរិះគន់ ដូចចំណុចទី៤ ប៉ុន្តែសរុបទៅគ្រូឧទ្ទេស បញ្ជាក់ថា មេរៀនរបស់គ្រូមិនសូវល្អទេ។

ប្រសិនមេរៀនមួយក្នុងចំណោមមេរៀនបន្ទាប់ ត្រូវបានទទួលតាមរបៀបតែមួយ គឺថាមេរៀននីមួយៗ បានទទួលចម្លើយ(១) ឬមេរៀននីមួយបានទទួលចម្លើយ(២)។ល។ តើអ្នកមានអារម្មណ៍បែបណា ក្រោយពេលមេរៀន៣០? គេស្ទើរពាល់គ្នា ហាក់មានអារម្មណ៍តានតឹងខ្លាំង រហូតដល់គេនឹងមានកម្លាំងជំរុញទឹកចិត្តខ្លាំងបំផុត ហើយសិក្សាបានរហ័សជាមួយចម្លើយតបស្រដៀងគ្នាតាមបែបបទ(៤)ខាងលើ។ វាកំពុងត្រូវបានលើកទឹកចិត្តក្នុងរឿងនោះ ដែលទទួលបានជោគជ័យ ប៉ុន្តែចូរផ្តល់នូវចំណុចសំខាន់ៗនូវរបៀបទាំងឡាយនៃការទទួលកម្រិតស្តង់ដាខ្ពស់ជាងក្នុងពេលអនាគត។

វាទំនងបំផុត ដែលសិស្សក្នុងថ្នាក់រៀនអ្នក និងផ្សេងពីអ្នកតាមប្រតិកម្មចិត្តរំភើបរបស់គេ ចំពោះការសរសើរ និងការរិះគន់។ ពួកគេ នឹងស្អប់ការមិនយកចិត្តទុកដាក់ គេនឹងត្រូវបានលើកទឹកចិត្ត តាមការសរសើរ ហើយដរាបណាភាពជោគជ័យទាំងឡាយណា ត្រូវបានគេទទួលស្គាល់និងសរសើរ ពួកគេនឹងទំនងជារកឃើញការរិះគន់ដោយស្ថាបនាដោយសមហេតុផលណាមួយ ដើម្បីបញ្ចេញសមត្ថភាពជាជាងការបាក់ទឹកចិត្ត។

វាមានតម្លៃនឹងនិយាយថា សូម្បីតែសិស្សខ្សោយ ក៏អាចត្រូវបានសរសើរ សម្រាប់ភាពជោគជ័យ និងកំណែលម្អដ៏តិចតួចរបស់គេដែរ។ ប្រសិនបើសិស្សខ្សោយស៊ូទទួលយកប្រតិកម្ម(១) ឬ(៣)គេនឹងបោះបង់ចោលជាយថាហេតុ។ គ្រូវិញ ក៏ដូចច្នេះដែរ។ គេបានលើកឡើង"គ្រឿងចក្រជំរុញការសិក្សា"ដែលបានបញ្ជាក់ច្បាស់លាស់ថា ប្រសិនបើសិស្សនឹងមិនទទួលបានជោគជ័យ តាមទម្រង់នៃការ

លើកទឹកចិត្តមួយចំនួនទេ ការសិក្សានឹងមិនប្រព្រឹត្តបានល្អឡើយ[2]។

ប្រសិនបើការសរសើរ ស្ងើយសរសើរ ឬទម្រង់នៃការលើកទឹកចិត្តផ្សេងទៀត ត្រូវផ្តល់រង្វាន់យ៉ាងហោចណាស់ សិស្សប្រាកដជាទទួលបានជោគជ័យតាមផ្នែក តាមកិច្ចការដែលគ្រូដាក់ឱ្យ។ ឱកាសអ្នកដើម្បីសរសើរ ឬលើកទឹកចិត្តដល់ការសិក្សា នឹងមានកម្រិតអតិបរមា ប្រសិនបើអ្នក៖

-កំណត់គោលដៅដែលអាចសម្រេចបានយ៉ាងហោចណាស់ កិច្ចការសិក្សាមួយចំនួន ដែលគ្រូដាក់ឱ្យនឹងសម្រេចបាន ដោយសិស្សម្នាក់ៗ តាមបញ្ហារាប់ម៉ោង ឬតិចជាងនេះ ដោយផ្តល់នូវពេលវេលាគ្រប់គ្រាន់ ឬប្រតិបត្តិកែតម្រូវ។ រឿងនេះតម្រូវថា កិច្ចការទាំងឡាយ នឹងត្រូវបានកំណត់ន័យបានល្អជាក់លាក់ ហើយនិងមិនផ្អែកលើខ្លាំងដល់ការសិក្សាពីមុនទេ។ បំណាន កម្រិតទាប ដូចជាការសាឡើងវិញ កិច្ចការសាមញ្ញ ដូចជាការគូរនិងការបិទផ្លាកលើដ្យាក្រាម ជារឿងសមរម្យឧទាហរណ៍ដូចជា ការពន្យល់ពីប្រយោជន៍បីយ៉ាងពីកសិដ្ឋានលើផ្ទៃរាបស្មើនៅជម្រាលភ្នំឬនិស្សិតផ្នែកវិទ្យាសាស្រ្ត ដែលកំពុងសិក្សាពីរបៀបអនុវត្ត ការគណនាដដែលៗតាមការជំនួសដ៏ត្រឹមត្រូវ ទៅជារូបមន្ត។

ប្រសិនបើសិស្សត្រូវបានវាយតម្លៃដោយរាប់បញ្ចូលទាំងការសរសេរអត្ថបទ ឬបំណិនការសរសេររបាយការណ៍ ដូច្នេះភាពទទួលបានជោគជ័យ នឹងទទួលបានជោគជ័យយ៉ាងសំខាន់។ បំណិនបែបនេះ ត្រូវការពេលវេលា ដើម្បីអភិវឌ្ឍ គឺត្រូវផ្អែកលើខ្លាំងទៅលើការសិក្សាពីពេលមុន ហើយពាក់ព័ន្ធលើបំណិនពុទ្ធិកម្រិតខ្ពស់។

-ចូរបំបែកកិច្ចការ កិច្ចការលំបាក ឬដែលត្រូវបានពន្យាពេល គួរតែបំបែក ទៅជាផ្នែកដែលអាចគ្រប់គ្រងបាន ដែលត្រូវបានប្រតិបត្តិ និងទទួលបានរង្វាន់ដោយឡែកពីគ្នា។ មានតែពេលដែលជោគជ័យ បានសម្រេចលើជំហានមួយ គឺជាជំហានបន្ទាប់មួយដែលបានសាកល្បង។

-ផ្តល់ពេលវេលាដល់ការសិក្សា ពេលវេលាគួរតែផ្តល់ឱ្យសិស្សប្រតិបត្តិ រហូតដល់ចំណេះចំណាន នៃការសិក្សាបានសម្រេច។ ការធ្វើតេស្តឡើងវិញ និងប្រតិបត្តិឡើងវិញគួរតែទទួលបាន ដើម្បីឱ្យសិស្សជាយថាហេតុទទួលបានជោគជ័យ សូម្បីតែគេបរាជ័យនៅពេលដំបូងក៏ដោយ។

-ចូរសរសើរភាពជោគជ័យទៅតាមផ្នែក អ្នកគួរតែស្វែងរកអ្វីមួយ ដើម្បីធ្វើឱ្យសប្បាយក្នុងគ្រប់ផ្នែកនៃកិច្ចការ។ ជាញឹកញាប់

---

[2] ក្រសួងអ.យ.ក. **គរុកោសល្យ** នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំសិក្សា ១៩៩៥-៩៦ ទំព័រ៤០។

អ្នកនឹងរកឃើញអ្វីមួយត្រឹមត្រូវ ប្រសិនបើអ្នកប្រុងប្រយ័ត្ន។

-សរសេរការខិតខំប្រឹងប្រែង ការរីកចម្រើន និងសមិទ្ធផលនៃកិច្ចការសាមញ្ញ ព្រមទាំងការសម្រេចបានយ៉ាងត្រចះត្រចង់ នឹងមិនដែលដាក់បន្ទឹងដល់ការសរសើរចំពោះអ្នកដែលមានសម្បទា និងសេចក្ដីឈ្លាសវៃទេ[3]។

**១-តើយើងគួរតែសរសើរ និងទិតៀនយ៉ាងដូចម្ដេច**?

គ្រូមិនអាចបង្រៀន ដោយគ្មានការទិតៀនទេ ប៉ុន្តែ មនុស្សភាគច្រើន មិនចូលចិត្តការទិតៀនទេ។ តើគ្រូអាចធ្វើឱ្យថ្នាំគ្រាប់ល្វីងទៅជាផ្អែមបានយ៉ាងដូចម្ដេចទៅ? គ្រូដែលមានបទពិសោធ អាចរិះគន់ស្នាដៃសិស្ស ដោយស្មើរតែមិនឱ្យសិស្សដឹងរឿងនេះទេ។ ចូរអានឧទាហរណ៍ខាងក្រោម[4]៖

តើគ្រូ អាចមើលឃើញថា គាត់អនុវត្ត វាយ៉ាងដូចម្ដេច?

១-ប្រសើរណាស់ តារាងបានប្រសើរជាងមុនហើយឥឡូវនេះ។ ទោះជាយ៉ាងណាក៏ដោយ ចូរប្រើខ្មៅដៃ ដូច្នេះ អ្នកអាចលុបកំហុសបាន។ ចំណុចទាំងអស់ ដែលមើលទៅហាក់ដូចជារៀបចំដំណើររឿងបានត្រឹមត្រូវហើយ ល្អប្រសើរណាស់។

ចូរប្រៀបធៀបឧទាហរណ៍ខាងលើជាមួយ "ចូរកុំប្រើប៊ិក ដើម្បីគូសតារាង"។

២-ចូររក្សាវាជាកាលអនាគតកាលសិលា តើអ្នកអាចមើលឃើញពីកន្ទែង ដែលអ្នកធ្វើឱ្យវាទៅជាអតីតកាលទេ? មែនហើយ នេះណែ៎! ខ្ញុំចង់ឱ្យល្បះអ្នកមានន័យបើកទូលាយ។

ចូរប្រៀបធៀបឧទាហរណ៍ខាងលើជាមួយ៖ ចូរកុំច្របល់កាលរបស់អ្នក។

-ការរិះគន់គួរតែមានលក្ខណៈស្ថាបនា។ នោះគឺថា យើងគួរតែលើកឡើងពីអ្វីដែលខុស និងត្រូវ ពន្យល់អ្វីដែលត្រូវកែកំហុស។ រឿងនេះ ធ្វើឱ្យសិស្សមើលឃើញការរិះគន់ថា ជាការផ្ដល់ដំបូន្មានទៅវិញ។ "ចូរខិតខំប្រឹងប្រែងបន្តទៀត" ជាជាង "នោះមិនមែនជាអ្វីដែលខ្ញុំប្រាប់អ្នកឱ្យធ្វើទេ"។

-ការរិះគន់ គួរមានលក្ខណៈវិជ្ជមានជាជាងអវិជ្ជមាន៖ លឿនឡើង សុខា ចាប់ផ្ដើមទៅ" ហើយមិនមែន "កុំប្រព្រឹត្តភ្លីភ្លើដូច្នោះ"។ "ចូរប្រើខ្មៅដៃ" ជាជាង "កុំប្រើប៊ិក"។

-ប្រសិនបើអាចធ្វើទៅបាន ចូរផ្សំការរិះគន់ និងការសរសើរ ហើយបញ្ចប់ដោយការសរសើរ។

រឿងទាំងអស់នេះ នឹងជួយសិស្សគ្រូឱ្យទទួលយកការរិះគន់ដោយសមរម្យ ហើយ

[3] Geoffrey Petty, *Teaching Today*, a course book for Cert Ed, B Ed., p.54-55, Spain, 2011.

[4] Geoffrey Petty, *Teaching Today*, a course book for Cert Ed, B Ed., op. cit., p. 56-59.

*សិក្សាដោយវិជ្ជមាន ឆ្ពោះទៅរកភាពប្រសើរជាងមុន។ វានឹងបង្កើតផងដែរនូវបរិយាកាសវិជ្ជមានក្នុងថ្នាក់រៀនរបស់ខ្លួន គ្មានអ្នកណាម្នាក់ ចូលចិត្តមនុស្សរិះគន់ដដែលៗទេ។*

*ចូរព្យាយាមកុំរិះគន់ស្នាដៃសិស្សខ្លាំងពេក ផ្ទុយទៅវិញ ចូរផ្តល់ឱ្យសិស្សនូវឱកាសមួយ ដើម្បីព្យាយាមម្តងទៀត។ ជាឧទាហរណ៍ សុំសិស្សឱ្យធ្វើឡើងវិញ ឬកែលម្អការសិក្សារហូតដល់គេបានទទួលពិន្ទុល្អសមរម្យ។*

*ការសរសើរបង្កើនកម្លាំងជាខ្លាំង តាមទំនាក់ទំនងកែវភ្នែក ជាពិសេសប្រសិន បើរឿងនេះ មានការគាំទ្រ និងអមដោយភាពញញឹម។ ការសរសើរបុគ្គលម្នាក់ មានឥទ្ធិពលខ្លាំងការសរសើរទូទាំងថ្នាក់រៀនទាំងមូល។ ការសរសើរដោយឥតគ្រោងទុក មានឥទ្ធិពលខ្លាំងជាងគេ។  ចូរព្យាយាមហៅសិស្សដែលអង្គុយនៅខាងក្រោយថ្នាក់ ហើយបន្ទាប់មកនិយាយអ្វីមួយវិជ្ជមានអំពីការសិក្សារបស់គេ។ ការសរសើរ ក៏បង្កើនកម្លាំងខ្លាំងផងដែរ តាមភាពពិស្តារ។ "អ្វីដែលខ្ញុំចូលចិត្តអំពីអត្ថបទរបស់អ្នកគឺ....”។*

*ការសរសើរ គឺជាទម្រង់តែមួយគត់នៃអ្វីដែលចិត្តវិទូអាកប្បកិរិយា ហៅថា "ការជំរុញលើកទឹកចិត្តជាវិជ្ជមាន”។ លោក ស្គីន័រ កំណត់ន័យរឿងនេះថាជា "ចម្លើយតបដល់ភាពជោគជ័យសិស្ស ជាជាងភាពបរាជ័យរបស់គេ”។ មានមធ្យោបាយជាច្រើននៃការលើកទឹកចិត្តការខិតខំប្រឹងប្រែងរបស់សិស្សដើម្បីសិក្សា ដូចដែលប្រអប់ខាងក្រោមនឹងបង្ហាញ។*

*-ការជំរុញលើកទឹកចិត្ត គួរតែធ្វើទៅតាមលទ្ធភាព និងគួរតែធ្វើដល់សិស្សគ្រប់គ្នា។*

**ទម្រង់នៃការលើកទឹកចិត្តជាវិជ្ជមាន ផ្នែកខាងក្រៅ(ខាងក្រៅខ្លួនសិស្ស)**

**គ្រូបង្រៀន**

*-ផ្តល់ការយកចិត្តទុកដាក់ដល់សិស្ស*

*-គោរពសិស្សថាជាមនុស្សម្នាក់ និងបង្ហាញភាពកក់ក្តៅដល់គេ*

*-ស្តាប់ដោយបង្កើនកម្លាំងចិត្តបន្ថែមដល់សិស្ស*

*-ទទួលយកគំនិតពីសិស្ស*

*-ប្រើប្រាស់ស្នាដៃកិច្ចការសិស្ស ដោយយកជាអ្នកផ្តល់ឧទាហរណ៍*

*-ចំណាយពេលវេលាជាមួយសិស្ស*

*-សើចសប្បាយនឹងរឿងកំប្លែងសិស្ស*

*-បង្ហាញនូវការគោរពខ្លាំងដល់សិស្ស*

*-ផ្តល់កម្រិតពិន្ទុ និងចំណាត់ថ្នាក់*

*-សរសេរមូលវិចារ លើកិច្ចការសរសេររបស់សិស្ស*

*-ផ្តល់ការញញឹមទំនាក់ទំនងតាមកែវភ្នែក*

*-គូសនៅខាងដើមទំព័រ ដើម្បីឆ្លើយតបទៅនឹងចំណុចល្អ ដែលបានបង្កើតអត្ថបទ*

*-តាំងបង្ហាញស្នាដៃសិស្ស*

*-ផ្តល់ឯកសិទ្ធិពិសេស*

*ការសរសើរពីមិត្តភក្តិ ឪពុកម្តាយ និងអ្នកផ្សេងការធ្វើតេស្ត ឬប្រឡងជាប់*

អ្វីមួយដែលមានប្រយោជន៍ ដែលទាញចេញពីខ្លឹមសារមេរៀន។

**ផ្នែកខាងក្នុង(ខាងក្នុងខ្លួនសិស្ស) សិស្ស**

-សិក្សាប្រធានបទ ឬបញ្ចប់កិច្ចការមួយ ដែលមានប្រយោជន៍ដល់គេ

-ពេញចិត្តនឹងការចង់ចេះដឹងផ្ទាល់ខ្លួនរបស់គេ

-ស្រាវជ្រាវរកឃើញអ្វីមួយដោយខ្លួនឯង

-មានគំនិតច្នៃប្រឌិតមានគំនិតត្រួតពិនិត្យ

-ឆ្លើយតបនឹងការខិតខំបញ្ចេញអស់សមត្ថភាពខ្លួន

-គូសចំណាំបញ្ជីសមត្ថភាព ឬកិច្ចការ

-មានអារម្មណ៍ថា "ខ្ញុំអាចធ្វើបាន ខ្ញុំធ្វើវាបានត្រឹមត្រូវ"

-សម្រេចបានវត្ថុបំណងបុគ្គល ឬបំពេញកិច្ចការដែលដាក់ដោយខ្លួនឯង។

បច្ចេកទេសសិក្សា ទទួលបានចំណេះចំណាន មានភាពប្រសើរណាស់ សម្រាប់ការលើកទឹកចិត្តដល់ការសិក្សា។ សិស្សមួយចំនួនមើលឃើញការសរសើរជាសាធារណៈ ថាជាពាក្យបង្អាប់លើរូបភាព ដែលប្រឆាំងនឹងការស្ដាបនា។ ទោះជាយ៉ាងណាក៏ដោយ គេមិនទាន់បានឃើញសិស្សណាម្នាក់ ដែលមិនទទួលការសរសើរដោយម្នាក់ទល់នឹងម្នាក់ទេ។

ទាំងការជំរុញលើកទឹកចិត្ត ទាំងការរិះគន់ អាចផ្ដល់ជាផ្លូវការតាមមធ្យោបាយមិនផ្ទាល់មាត់។ជាឧទាហរណ៍ តាមការបង្ហាញទឹកមុខ តាមការដំឡើងសំឡេង តាមធ្វើមិនដឹងមិនឮ តាមកាយវិការ។ល។

ផលនៃស្ញ័យសរសើរ និងស្ញ័យរិះគន់ មានទំហំធំជាងគ្រូបានដឹង។ ជួនកាល ស្ញ័យសរសើរនេះ ត្រូវបានគេហៅថា ការលើកទឹកចិត្តផ្នែកខាងក្នុង និងទ្រឹស្ដីវិទូជាច្រើន ជឿជាក់ថា នេះជាកត្តាជំរុញទឹកចិត្ត ដ៏មានឥទ្ធិពលបំផុត តាមផ្នែក ពីព្រោះវាមានដំណើរការ នៅពេលដែលគ្រូមិននៅទីនោះ។ វាជាសេចក្ដីត្រេកត្រអាលនៃការពេញចិត្ត ដែលយើងទទួលបាន ពេលដែលយើងមានអារម្មណ៍ថា យើងបានធ្វើកិច្ចការមួយបានល្អ។ វាជាការជំរុញចិត្តផងដែរដែលយើងមាន ពេលដែលការសិក្សាអ្វីមួយ ជំរុញការចង់ចេះដឹង របស់យើង ឬពេលធ្វើអ្វីមួយគួរជាប់អារម្មណ៍។ សកម្មភាពច្នៃប្រឌិត ឬការងារណាមួយផ្សេងទៀត ដែលយើងអាចបង្ហាញបុគ្គលភាពរបស់យើង បង្កើតនូវកម្លាំងជំរុញចិត្តពីខាងក្នុងនេះ។

វាក៏មានស្ញ័យរិះគន់ផងដែរ។ សិស្សភាគច្រើនទទួលស្គាល់ថា នៅពេលដែលការសិក្សារបស់គេ ចុះខ្សោយ ឬពេលដែលអត្រាការងាររបស់គេយឺតជាងមុន គេត្រូវការប្រៀបធៀបស្នាដៃរបស់គេជាមួយ សិស្សផ្សេងទៀត ឬជាមួយនឹងអ្វីដែលគេដឹងថា គេអាចធ្វើបាន ប្រសិនបើព្យាយាម។ វាជារឿងបាក់ទឹកចិត្ត និងសោយចិត្តសម្រាប់សិស្សភាគច្រើន ដែលសិក្សាមិនបានល្អដូចដែលគេអាច។

## ២-ពេលដែលយើងគួរតែសរសើរ ឬរិះគន់[5]

កំហុសមួយដ៏សាមញ្ញបំផុត ពេលដែលគ្រូកំពុងសិក្សាគឺថា ពួកគេ មិនបានសរសើរគ្រប់គ្រាន់ទេ។ គេបានឃើញជាច្រើនដងក្នុងម៉ោងដំបូងៗនៃការបង្រៀន ហើយគេក៏មិនដែលបានឃើញគ្រូណាម្នាក់សរសើរបានច្រើនទេ។ ឧបមាថា អ្នកចាប់ផ្ដើមបង្រៀន នៅខែកញ្ញា ដោយមានសិស្សក្នុងថ្នាក់រៀន២០នាក់ ដែលអ្នកជួបបង្រៀន១ពេលក្នុងមួយសប្ដាហ៍ ហើយអ្នកសរសើរសិស្សម្នាក់ក្នុងមួយពេល។ សិស្សត្រូវរង់ចាំដល់ខែមិថុនា ដើម្បីដល់វេនរបស់គេ។ ប្រសិនបើអ្នកចង់ឱ្យសិស្សគ្រប់គ្នា ទទួលបានការសរសើរបន្តិចបន្តួចនៅគ្រប់មេរៀន ដូច្នេះ ជាមធ្យមអ្នកត្រូវសរសើរយ៉ាងហោចណាស់ ម្ដងរៀងរាល់ពីរនាទី។ វាហាក់ដូចជារឿងចម្លែក ដើម្បីអនុវត្តរឿងនេះរហូតដល់អ្នកមានភាពស៊ាំ។

វាជារឿងសាមញ្ញ សម្រាប់ការពន្យល់ដោយសរសេរ លើកិច្ចការសិស្សដោយមានការរាប់បញ្ចូល ទាំងការរិះគន់។ ប្រហែលជាអ្នកសង្ស័យថា តើអ្នកអាចរកឃើញការងារដែលសមនឹងសរសើរល្មមដើម្បីអាចសរសើរ ញឹកញាប់ ដូចដែលគេបានផ្ដល់យោបល់ទេ? កុំភ័យខ្លាចដើម្បីសរសើររឿងសាមញ្ញ។ ប្រសិនបើសិស្សធ្វើអ្វីពេញចិត្តនឹងអ្នកចង់បាន វាមិនអាចជាបុព្វហេតុសម្រាប់ភាពអ៊ិអរ អន់ថយ និងត្រេកអរទេ ប៉ុន្តែវាជាបុព្វហេតុដើម្បីការសរសើរ។

ដូចដែលចិត្តវិទូអាកប្បកិរិយាបានបង្ហាញ ការសរសើរកាន់តែធ្វើភ្លាម និងញឹកញាប់ ផលនៃការជំរុញទឹកចិត្តកាន់តែខ្លាំងក្លា។

### ការសម្រេចបាន និងការខិតខំប្រឹងប្រែង

សិស្សខ្លះ ធ្វើអ្វីមួយបានសម្រេចដោយមិនចាំបាច់ប្រឹងប្រែង អ្នកផ្សេងទៀត សម្រេចតិចតួច ទោះបីមានការប្រឹងប្រែងក៏ដោយ។ ពិតហើយការសម្រេចបាន គួរតែគត់ត្រាទុក និងទទួលស្គាល់។ ប៉ុន្តែ វាជាកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចបានរឿងនោះ ដែលគួរតែទទួលបាននូវរង្វាន់។ ប្រសិនបើគ្រាន់តែសរសើរសម្រេចបានផលនោះ អ្នកនឹងធ្វើឱ្យសិស្សខ្សោយគ្មានសេចក្ដីក្លាហាន និងធ្វើឱ្យសិស្ស មានលទ្ធភាពខ្ជិលច្រអូស។

ប៉ុន្តែ តើសិស្សខ្សោយសមនឹងទទួលការសរសើរទេ? ចម្លើយគឺត្រូវបានបញ្ជាក់ដោយយល់ព្រម។

ពិតហើយសិស្សខ្សោយ សមនឹងទទួលរឿងនេះខ្លាំងណាស់។ ពួកគេត្រូវតែ តស៊ូ នឹងការសិក្សា ដែលកំពុងជួបប្រទះដោយមិនគិតពីលទ្ធភាពពីធម្មជាតិ ហើយការតស៊ូនេះ កម្រនឹងទទួលបានជោគជ័យណាស់។ ពួកគេទទួលរងការឈឺចាប់ពីការសម្លឹងមើលពី

[5] John W. Santrock, *Educational psycholo- gy*, McGraw Hill, United States of America, 2018. p.179.

សិស្សដែលមានសមត្ថភាព ដោយមើលងាយពួកគេ ថាពួកគេមិនសូវប្រឹងប្រែង។

សិស្សដែលខ្វះទំនុកចិត្ត ហាក់មានអារម្មណ៍បាក់ទឹកចិត្ត ឬមានតម្រូវការចង់បានការសរសើរខ្លាំងជាងអ្នកផ្សេង។ ម្តងម្កាល ការសរសើរមិនទទួលបានផលជា មួយសិស្សបែបនេះ។ ការសរសើរ និងការជំរុញលើកទឹកចិត្តផ្សេងទៀត គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតតែមួយ នៃការដោះស្រាយបញ្ហាអាកប្បកិរិយា។ ប្រសិនបើអ្នកមានបញ្ហាជាមួយសិស្សដែលមកយឺត ដូច្នេះចូរសរសើរអ្នកដែលមកទាន់ពេល។ ប្រសិនបើបញ្ហាជាមួយសិស្សមិនសូវយកចិត្តទុកដាក់ ចូរសរសើរសិស្សដែលផ្ចិតផ្ចង់យកចិត្តទុកដាក់។

នៅក្នុងកំឡុងពេលសិក្សា គេគួរតែមានការសរសើរឱ្យបានច្រើន និងការរិះគន់តាមបែបស្ថាបនា សម្រាប់គ្រប់សិស្សក្នុងការបង្រៀនជាក្រុម។ រឿងនេះ រំពឹងថានឹងធ្វើឱ្យបានច្រើន ហើយកុំគិតដល់ការខ្វះខាតពេលវេលាឱ្យសោះ។

ការសរសើរ ជួយឱ្យកម្រិតសិក្សារបស់សិស្សដល់អតិបរមា។ វាធ្វើឱ្យប្រសើរដល់ទំនាក់ទំនងគ្រូ និងសិស្សមានកាន់តែខ្លាំងឡើង។ វាធ្វើឱ្យកម្រិតរំខានធាតៅចុះជាអប្បបរមា ហើយនៅក្នុងការរៀបចំរយៈពេលវែង វាធ្វើឱ្យការបង្រៀនរបស់អ្នក មានភាពងាយស្រួលជាងមុន ផ្តល់ផលល្អច្រើន និងមានប្រសិទ្ធភាពងាយស្រួលជាងមុនយ៉ាងខ្លាំង។ ដូច្នេះ ហេតុអ្វីបានជាគ្រូមួយចំនួនធំ ទាញយកប្រយោជន៍ពីវាបានតិចតួច? ប្រហែលមកពីដោយសារៈ

-តាមស្ថានភាពជាក់ស្តែង វាជារឿងលំបាក ដើម្បីលើកទឹកចិត្តសិស្សទាំងអស់ឱ្យបានគ្រប់គ្រាន់ និងរិះគន់គេដោយស្ថាបនា ជាពិសេសសិស្សដែលខ្សោយជាងគេ និងសិស្សដែលពូកែជាងគេ។

-វារឿងលំបាកខ្លាំងណាស់ ដើម្បីប្រមូលផ្តុំសទ្ធាទានចិត្តរំភើបដើម្បីលើកទឹកចិត្តសិស្ស ដែលបាក់ទឹកចិត្ត។ រហូតមកដល់ពេលនេះ រឿងនេះ ត្រូវការការលើកទឹកចិត្តជាច្រើនបំផុត ហើយនិងនឹងធ្វើគ្រូឱ្យលំបាកបំផុត ប្រសិនបើសិស្ស មិនទទួលបានការលើកទឹកចិត្ត។

-គ្រូភាគតិចបំផុត ដែលមិនបានដឹងពីរបៀបសរសើរសិស្ស។

វាអាចជារឿងលំបាក ដើម្បីលើកទឹកចិត្តសិស្ស ហើយវាត្រូវការប្រតិបត្តិកែតម្រូវ ដើម្បីបង្កើនអត្រាការលើកទឹកចិត្តរបស់អ្នក។ ប៉ុន្តែ តាមការរៀបចំរយៈពេលវែង វាជារឿងលំបាកថែមទៀត ដែលមិនបានអនុវត្តដូច្នេះ។

## សន្និដ្ឋាន

ជារួមមក ការលើកសរសើរ និងការទិតៀនសិស្ស គឺជាកិច្ចការដ៏សំខាន់បំផុតរបស់គ្រូបង្រៀន នៅក្នុងការបង្រៀន និងការរៀនរបស់សិស្ស នៅក្នុងប្រទេសកម្ពុជាយើងនា

*ពេលបច្ចុប្បន្ន។ ប៉ុន្តែ គ្រូបង្រៀនមួយចំនួន មិនបានអនុវត្តការងារនេះ ឱ្យបានល្អប្រសើរ ទេ។ ជាទូទៅ គាត់គិតថា រឿងនេះ ជារឿង សាមញ្ញ មិនចាំបាច់ ដែលធ្វើឱ្យការបង្រៀន របស់គាត់ មានភាពអសកម្ម ហើយសិស្ស មិន មានចិត្តចលករក្នុងការសិក្សា និងនៅទីបំផុត លទ្ធផលនៃការសិក្សារបស់សិស្ស ទទួលបាន កម្រិតទាប ឬបរាជ័យតែម្តង។*

## ឯកសារយោង


1- Killen, Roy, *Effective teaching strategies: Lessons from research and practice,* Social science press. 2003.
2- Geoffrey Petty, *Teaching Today*, a course book for Cert Ed, B Ed, etc., Spain, 2011.
3- John W. Santrock, *Psychology*, McGraw Hill, United States of America, 2011
4- Stephen M. Kosslyn & Robin S. Rosenberg, *Psychology*, Pearson Education, 2004
5- John W. Santrock, *Educational psychology*, McGraw Hill, United States of America, 2018.
6- John W. Santrock and Alysia D. Roehrig, *Educational psychology*, McGraw Hill, United States of America, 2024.